**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et Des Sciences Economiques

Royal University of Law and Economics

# កិច្ចការស្រាវជ្រាវ

# ស្ដីពី

# ការផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាអូទីស្សឹមនៅមណ្ឌលសុខភាពក្រុងតាខ្មៅក្នុងខេត្តកណ្ដាល

រៀបរៀងដោយ ៖

និស្សិតឈ្មោះ ៖ **លាង សេងហ៊ុយ**

**តុប កន្និកា**

**ខុម កក្កដារាជ**

**ប៊ិន សម្បត្តិ**

**ច្រឹក សុម៉ាលី**

**ហ៊ារ រិទ្ធាវី**

**ហ៊ីម សុភាព**

**រី ស្រីពេជ្រ**

បង្រៀនដោយ ៖

បណ្ឌិត **ព្រុំ ទេវី**

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង

ជំនាន់២២ ជំហាន១ ក្រុមB ឆ្នាំទី២ ឆមាសទី១

ឆ្នាំសិក្សា : ២០២៥~២០២៦

# មាតិកា

សារតាគម្រោង.......................................................................................................i

## ជំពូកទី១ : ការរៀបចំផែនការគម្រោង

១.១. ឈ្មោះគម្រោង.......................................................................................................១

១.២. គោលបំណង.......................................................................................................១

១.៣. គោលដៅ.......................................................................................................១

១.៤. សកម្មភាព.......................................................................................................១

១.៥. ប្រភពថវិកា.......................................................................................................៣

១.៦.អ្នកទទួលខុសត្រូវ.......................................................................................................៣

១.៧. សូចនាករ.......................................................................................................៥

១.៨. មធ្យោបាយផ្ទៀងផ្ទាត់.......................................................................................................៧

១.៩. ហានិភ័យ.......................................................................................................៩

## ជំពូកទី២ : ដំណើរការគម្រោង

២.១. ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង.......................................................................................................១២

២.២. ការប្រើប្រាស់ផែនការពេលវេលា.......................................................................................................១៣

២.៣. ការប្រើប្រាស់ធនធានគម្រោង.......................................................................................................១៥

២.៤. ការកំណត់ប្រភពថវិកា.......................................................................................................១៦

២.៥. ការតាមដាន ការវាយតម្លៃ និងការតាមដានបន្ត.......................................................................................................១៦

២.៦. ការបញ្ចប់គម្រោង.......................................................................................................១៦

២.៧. ការវិភាគ SWOT.......................................................................................................១៧

**សេចក្តីសន្និដ្ឋាន**.......................................................................................................១៨

# សារតាគម្រោង

បញ្ហាអូទីស្សឹម គឺជាបញ្ហាសុខភាពផ្លូវចិត្តមួយដែលកើតមានឡើងក្នុងសង្គមទូទៅមិនថានៅក្នុងប្រទេសកម្ពុជានិងនៅសកលលោកដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ផ្លូវចិត្ត និងការប្រាស្រ័យទាក់ទងរបស់កុមារ ប៉ុន្តែការយល់ដឹងរបស់សាធារណៈជនពាក់ព័ន្ធនឹងបញ្ហានេះ ឬជួនកាលពីក្រុមគ្រួសាររបស់កុមារដែលមានបញ្ហាផ្ទាល់គឺនៅមានកម្រិតនៅឡើយ។ ដោយសារតែមិនទាន់មានការយល់ដឹងទូលំទូលាយពីបញ្ហានេះ កុមារដែលមានអូទីស្សឹមជាញឹកញាប់ត្រូវប្រឈមមុខនឹងការរើសអើង ការមិនយល់ចិត្ត និងការខ្វះការគាំទ្រពីមជ្ឈដ្ឋានជុំវិញខ្លួនមួយចំនួន ជាពិសេសមិនថាតែកុមារដែលមានបញ្ហាទេ ក្រុមគ្រួសាររបស់ពួកគេផ្ទាល់ក៏រងការប៉ះពាល់ផ្លូវចិត្ត និងការរើសអើងផងដែរ ក្នុងខណៈពេលដែលកុមារទាំងអស់ មិនថាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ គឺគួរតែទទួលបានការស្រលាញ់ ការថែទាំ និងការរាប់អានដោយស្មើភាពគ្នានឹងកុមារដទៃទៀតក្នុងសង្គម។

ក្នុងន័យនេះ ការផ្សព្វផ្សាយចំណេះដឹងអំពីបញ្ហាអូទីស្សឹមគឺជាកត្តាសំខាន់មួយ ដើម្បីជួយឲ្យសាធារណៈជន និងអ្នកពាក់ព័ន្ធទាំងអស់បានយល់ដឹងកាន់តែច្បាស់ពីអាការៈ អារម្មណ៍ និងតម្រូវការពិសេសរបស់កុមារអូទីស្សឹម។ ការយល់ដឹងនេះនឹងជួយលើកកម្ពស់ការយល់ចិត្ត ការគោរពសិទ្ធិកុមារ និងការបង្កើតបរិយាកាសសង្គមមួយដែលមានភាពយោគយល់ និងផ្តល់នូវការអោយតម្លៃគ្នាទៅវិញទៅមក។ ដោយហេតុនេះ គម្រោង «ការផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាអូទីស្សឹមនៅមណ្ឌលសុខភាពក្រុងតាខ្មៅក្នុងខេត្តកណ្ដាល» ត្រូវបានរៀបចំឡើង ដើម្បីចូលរួមលើកកម្ពស់ការយល់ដឹង កាត់បន្ថយការរើសអើង និងផ្តល់ការលើកទឹកចិត្តដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ។

មណ្ឌលសុខភាពក្រុងតាខ្មៅជាបណ្តុំនៃទីប្រជុំជនមួយ ដែលគ្រប់គ្នាបានមកទទួលការពិនិត្យជំងឺទូទៅក្នុងនោះនៅទីនេះ ក៏មានផ្តល់ការប្រឹក្សា ការវិនិច្ឆ័យពាក់ព័ន្ធនឹងបញ្ហាអូទីស្សឹមផងដែរ ប៉ុន្តែនៅមិនទាន់ឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការនៅឡើយទេ។ ដោយមណ្ឌលសុខភាពក្រុងតាខ្មៅជាបណ្តុំនៃទីប្រជុំជនផង និងមានក្រុមគ្រួសារដែលមានបញ្ហាអូទីស្សឹមច្រើនផង ក្រុមរបស់យើងខ្ញុំក៏បានសម្រេចធ្វើការផ្សព្វផ្សាយនៅទីតាំងនេះផ្ទាល់តែម្តង។

# ជំពូកទី១ ការរៀបចំផែនការគម្រោង

## ១.១. ឈ្មោះគម្រោង

គម្រោងនេះមានឈ្មោះថា «ការផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាអូទីស្សឹមនៅមណ្ឌលសុខភាពក្រុងតាខ្មៅក្នុងខេត្តកណ្តាល»។

## ១.២. គោលបំណង

លើកកម្ពស់ការយល់ដឹងពីបញ្ហាអូទីស្សឹម ការស្វែងយល់ពីអារម្មណ៍របស់កុមារជាពិសេសក្រុមគ្រួសារដែលមានបញ្ហានេះ ដើម្បីកាត់បន្ថយការរើសអើង និងផ្តល់ការលើកទឹកចិត្តដល់ពួកគាត់។

## ១.៣. គោលដៅ

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។
- **គោលដៅទី២** : ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ២០២៦។
- **គោលដៅទី៣** : ត្រួតពិនិត្យការចំណាយ និងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចការផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធ និងសាធារណៈជនចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់ សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៤. សកម្មភាព

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព១.១** : បង្កើតក្រុមការងារ ធ្វើផែនការគម្រោង បែងចែកភារកិច្ច តួនាទីសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។
  - **សកម្មភាព១.២** : ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយធ្វើសកម្មភាពផ្សព្វផ្សាយនិងរៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់ សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។
  - **សកម្មភាព១.៣** : ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬអ្នកពាក់ព័ន្ធដើម្បីស្នើសុំការសហការ និងរៀបចំលើកិច្ចការរដ្ឋបាល ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

- **សកម្មភាព១.៤ :** ការជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាន និង ការរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ (សម្ភារ : ការតុបតែង ទីតាំង ឯកសារ វត្ថុអនុស្សាវរីរង្វាន់ផ្សេងៗ) ចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

- **គោលដៅទី២ :** ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព២.១ :** ការដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹក រួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តការកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព២.២ :** ការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិង ភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព២.៣ :** ការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព២.៤ :** រៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **គោលដៅទី៣ :** ត្រួតពិនិត្យ ការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃការងារផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារណជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។
  - **សកម្មភាព៣.១ :** ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល ចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។
  - **សកម្មភាព៣.២ :** រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។
  - **សកម្មភាព៣.៣ :** ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យបានត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។
  - **សកម្មភាព៣.៤ :** ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៥. ប្រភពថវិកា

ប្រភពថវិកា ដើម្បីធ្វើការគាំទ្រគម្រោងនេះគឺបានមកពីជំនួយរបស់អង្គ ដៃគូសហការ និងមូលនិធិអែងគ្លាស។

## ១.៦. អ្នកទទួលខុសត្រូវ

ដើម្បីអនុវត្តគម្រោងនេះទទួលបានលទ្ធផលល្អ តម្រូវឱ្យមានការបែកចែកភារកិច្ចនិងទំនួលខុសត្រូវលើសកម្មភាពនីមួយៗពីក្រុមការងារដូចខាងក្រោមៈ

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។
  - សកម្មភាព១.១ : បង្កើតក្រុមការងារធ្វើផែនការគម្រោងបែងចែកភារកិច្ចតួនាទីសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។
    អ្នកទទួលខុសត្រូវ : **លោកស្រី ហ៊ រិទ្ធារី**
  - សកម្មភាព១.២ : ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយ ធ្វើសកម្មភាពផ្សព្វផ្សាយនិងរៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់ សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។
    អ្នកទទួលខុសត្រូវ : **លោកស្រី រី ស្រីពេជ្រ**
  - សកម្មភាព១.៣ : ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬអ្នកពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការ និងរៀបចំលើកិច្ចការរដ្ឋបាលចាប់ពីសប្តាហ៍ទី១ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។
    អ្នកទទួលខុសត្រូវ : **កញ្ញា ហ៊ីម សុភាព**
  - សកម្មភាព១.៤ : ការជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាននិងការរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ( សម្ភារៈ ការតុបតែងទីតាំង ឯកសារ វត្ថុអនុស្សាវរីយ៍ រង្វាន់ផ្សេងៗ ) ចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។
    អ្នកទទួលខុសត្រូវ : **លោក ខុម កក្កដារាជ**
- **គោលដៅទី២** : ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
  - សកម្មភាព២.១ : ដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹករួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។
    អ្នកទទួលខុសត្រូវ : **លោក ប៊ិន សម្បត្តិ**
  - សកម្មភាព២.២ : សម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវ : **លោក លាង សេងហ៊ុយ**

- សកម្មភាព២.៣ : ផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

  អ្នកទទួលខុសត្រូវ : **កញ្ញា ច្រឹក សុម៉ាលី**
- សកម្មភាព២.៤ : រៀបចំពិធីបិទកម្មវិធីនិងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

  អ្នកទទួលខុសត្រូវ : **លោក ប៊ិន សម្បត្តិ**

- **គោលដៅទី៣ :** ត្រួតពិនិត្យការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃការងារផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

  - សកម្មភាព៣.១ : ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូលចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

    អ្នកទទួលខុសត្រូវ : **កញ្ញា តុប កន្និកា**
  - សកម្មភាព៣.២ : រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

    អ្នកទទួលខុសត្រូវ : **កញ្ញា ច្រឹក សុម៉ាលី**
  - សកម្មភាព៣.៣ : ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

    អ្នកទទួលខុសត្រូវ : **លោកស្រី ហ៊ារ វិទ្ធារី**
  - សកម្មភាព៣.៤ : ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហទី៣ ខែតុលា ឆ្នាំ២០២៦។

    អ្នកទទួលខុសត្រូវ : **កញ្ញា ហ៊ីម សុភាព**

## ១.៧. សូចនាករ

ដើម្បីងាយស្រួលក្នុងការផ្ទៀងផ្ទាត់ វាស់វែង វាយតម្លៃនៃការអនុវត្តសកម្មភាពគម្រោង យើងត្រូវមានសូចនាករដូចខាងក្រោម៖

- **គោលដៅទី១ :** បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព១.១ : បង្កើតក្រុមការងារ ធ្វើផែនការគម្រោង បែងចែកតួនាទី ភារកិច្ចសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

- **សូចនាករ១.១ :** ក្រុមការងារបានចេញសេចក្តីសម្រេចស្តីពីការបែងចែកតួនាទី ភារកិច្ចសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

សកម្មភាព១.២ : ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយ ធ្វើសកម្មភាពផ្សព្វផ្សាយនិងរៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់ សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។

- **សូចនាករ១.២ :** ក្រុមការងារបានកំណត់តម្រូវការនៃការចំណាយក្នុងគម្រោងទាំងមូល បន្ទាប់មកធ្វើការផ្សព្វផ្សាយនិងរៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។

សកម្មភាព១.៣ : ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬអ្នកពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការ និងរៀបចំលើកិច្ចការរដ្ឋបាល ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

- **សូចនាករ១.៣ :** ក្រុមការងារបានធ្វើការទំនាក់ទំនងសុំកិច្ចសហការពីភាគីពាក់ព័ន្ធ និងរៀបចំឯកសារតម្រូវផ្សេងៗ ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

សកម្មភាព១.៤ : ក្រុមការងារបានធ្វើការទំនាក់ទំនងសុំកិច្ចសហការពីភាគីពាក់ព័ន្ធ និងរៀបចំឯកសារតម្រូវផ្សេងៗ ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

- **សូចនាករ១.៤ :** ក្រុមការងារបានប៉ាន់ស្មានចំនួនអ្នកចូលរួមនិងដឹកជញ្ជូនសម្ភារៈចាំបាច់សម្រាប់ថ្ងៃផ្សព្វផ្សាយដែលបានរៀបចំរួចរាល់ទៅមណ្ឌលសុខភាពក្រុងតាខ្មៅចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

- **គោលដៅទី២ :** ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.១ : ការដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹក រួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **សូចនាករ២.១ :** ក្រុមការងារទៅដល់មណ្ឌលសុខភាពក្រុងតាខ្មៅមុនម៉ោង៧ព្រឹក រួចចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.២ : ការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **សូចនាករ២.២ :** ក្រុមការងារជួយសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.៣ : ការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **សូចនាករ២.៣ :** ក្រុមការងារនិងវាគ្មិនកិត្តិយសផ្សព្វផ្សាយអំពីបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.៤ : រៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ខែកញ្ញា ឆ្នាំ២០២៦។

- **សូចនាករ២.៤ :** ក្រុមការងាររៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **គោលដៅទី៣ :** ត្រួតពិនិត្យ ការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារៈជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់ សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

សកម្មភាព៣.១ : ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល ចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

- **សូចនាករ៣.១ :** ក្រុមការងារបានបូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូលនិងបានចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព៣.២ : រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

- **សូចនាករ៣.២ :** ក្រុមការងារបានរៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

សកម្មភាព៣.៣ : ពិនិត្យនិងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

- **សូចនាករ៣.៣ :** ក្រុមការងារបានពិនិត្យនិងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវឱ្យស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

សកម្មភាព៣.៤ : ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហទី៣ ខែតុលា ឆ្នាំ២០២៦។

- **សូចនាករ៣.៤ :** ក្រុមការងារបានប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៨. មធ្យោបាយផ្ទៀងផ្ទាត់

ដើម្បីផ្ទៀងផ្ទាត់សកម្មភាពនីមួយៗយើងបានកំណត់នូវមធ្យោបាយផ្ទៀងផ្ទាត់ដូចខាងក្រោម៖

- **គោលដៅទី១ :** បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព១.១ : បង្កើតក្រុមការងារធ្វើផែនការគម្រោង បែងចែកភារកិច្ច តួនាទីសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់១.១ :** តារាងបញ្ជីរាយនាមក្រុមការងារចំនួន៨នាក់។

សកម្មភាព១.២ : ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយសម្រាប់ការផ្សព្វផ្សាយនិងអែអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់១.២ :** តារាងបញ្ជីចំណាយថវិកា

សកម្មភាព១.៣ : ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬភាគីពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការ និងរៀបចំលើកិច្ចការរដ្ឋបាល ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់១.៣:** បញ្ជីឈ្មោះស្ថាប័ន ឬភាគីពាក់ព័ន្ធ។

សកម្មភាព១.៤ : ជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាន និងរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ (សម្ភារៈ ការតុបតែងទីតាំង ឯកសារ វត្ថុអនុស្សាវរីយ៍ រង្វាន់ផ្សេងៗ) ចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់១.៤ :** បញ្ជីរាយសម្ភារៈសម្រាប់ថ្ងៃចុះផ្សាយ។

- **គោលដៅទី២ :** ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.១ : ដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹក រួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់២.១:** បញ្ជីស្រង់វត្តមានក្រុមការងារ។

សកម្មភាព២.២ : ការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់២.២:** បញ្ជីឈ្មោះអ្នកចូលរួម។

សកម្មភាព២.៣ : ការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់២.៣ :** កាលវិភាគកម្មវិធីផ្សព្វផ្សាយ។

សកម្មភាព២.៤ : រៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់២.៤:** កម្រងរូបភាពនៃកម្មវិធី។

- **គោលដៅទី៣ :** ត្រួតពិនិត្យការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

សកម្មភាព៣.១ : ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល រួចចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់៣.១:** បញ្ជីរាយមុខការចំណាយ និងវិក័យប័ត្រទូទៅ។

សកម្មភាព៣.២ : រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

➢ **មធ្យោបាយផ្ទៀងផ្ទាត់៣.២ :** បញ្ជីរាយនាមអ្នកចូលរួម និងកម្រងរូបភាពនិងវីដេអូនៃសកម្មភាពចុះផ្សព្វផ្សាយ។

សកម្មភាព៣.៣ : ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់៣.៣ :** បញ្ជីរាយនាមអ្នកចូលរួម និងបញ្ជីរាយមុខការចំណាយ។

សកម្មភាព៣.៤ : ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

- **មធ្យោបាយផ្ទៀងផ្ទាត់៣.៤ :** លិខិតបញ្ជាក់ការទទួលបាននូវរបាយការណ៍ពីអ្នកដែលពាក់ព័ន្ធ។

## ១.៩. ហានិភ័យ

- **គោលដៅទី១ :** បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព១.១ : បង្កើតក្រុមការងារ ធ្វើផែនការគម្រោង បែងចែកតួនាទី ភារកិច្ច សម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

- **ហានិភ័យ១.១ :** ពុំមានសមាជិកគ្រប់គ្រាន់ក្នុងការធ្វើការងារ។

សកម្មភាព១.២ : ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយធ្វើសកម្មភាពផ្សព្វផ្សាយនិងរៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់ សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។

- **ហានិភ័យ១.២ :** ការវាយតម្លៃអំពីតម្រូវការនៃការចំណាយមិនត្រឹមត្រូវ ហើយថវិកាដែលរៃអង្គាសពុំគ្រប់គ្រាន់តាមគម្រោងដែលបានកំណត់។

សកម្មភាព១.៣ : ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬភាគីពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការ និងរៀបចំលើកិច្ចការរដ្ឋបាល ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។

- **ហានិភ័យ១.៣ :** ស្ថាប័នពាក់ព័ន្ធមិនផ្តល់ការសហការដល់ក្រុមការងារ។

សកម្មភាព១.៤ : ការជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាន និងការរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ (សម្ភារៈ ការតុបតែងទីតាំង ឯកសារ វត្ថុអនុស្សាវរីយ៍ រង្វាន់ផ្សេងៗ) ចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ១.៤ :** ការរៀបចំសម្រាប់ថ្ងៃចុះផ្សព្វផ្សាយមិនទាន់ពេលវេលាកំណត់។

- **គោលដៅទី២ :** ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

សកម្មភាព២.១ : ការដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹក រួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ២.១ :** ក្រុមការងារមានធុរៈផ្ទាល់ខ្លួនសំខាន់ដែលមិនអាចចូលរួមបាន។

សកម្មភាព២.២ : ការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ២.២ :** មិនមានអ្នកចូលរួម ឬអ្នកចូលរួមក្នុងការផ្សព្វផ្សាយតិចជាងការរំពឹងទុកខ្លាំង។

សកម្មភាព២.៣ : ការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ២.៣ :** វាគ្មិនកិត្តិយសមិនអាចមកចូលរួមបាន។

សកម្មភាព២.៤ : រៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ២.៤ :** អ្នកចូលរួមអាចមានភារកិច្ចបន្ទាន់ត្រូវចាកចេញមុនពេលបញ្ចប់កម្មវិធី។

- **គោលដៅទី៣ :** ត្រួតពិនិត្យ ការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

សកម្មភាព៣.១ : ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល ចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

- **ហានិភ័យ៣.១ :** បាត់វិក័យបត្រចំណាយ ហើយកាំមេរ៉ាខូចដែលមិនអាចទាញយកកម្រងរូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយមកវិញបាន។

សកម្មភាព៣.២ : រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

- **ហានិភ័យ៣.២ :** ការរៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយមានភាពយឺតយ៉ាវ។

សកម្មភាព៣.៣ : ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

- **ហានិភ័យ៣.៣ :** មិនមានអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិនិត្យ និងកែសម្រួលរបាយការណ៍។

សកម្មភាព៣.៤ : ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

- **ហានិភ័យ៣.៤ :** រោងពុម្ពមិនអាចបោះពុម្ពរបាយការណ៍ទាន់ពេលវេលា។

# ជំពូកទី២ ដំណើរការគម្រោង

## ២.១. ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង

### ក. រចនាសម្ព័ន្ធនិង ទំនួលខុសត្រូវ

ក្រុមការងារចំនួន ៨នាក់បានធ្វើការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

| ល.រ | តួនាទី | ការទទួលខុសត្រូវ |
|---|---|---|
| ១ | ប្រធានគម្រោង | បង្កើតក្រុមការងារធ្វើផែនការគម្រោង បែងចែកភារកិច្ចតួនាទីសម្រាប់សមាជិកម្នាក់ៗ ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណង |
| ២ | អនុប្រធានគម្រោង | រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយ ជួយកែសម្រួលរបាយការណ៍តាមការណែនាំរបស់ប្រធាន និងចូលរួមក្នុងការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន |
| ៣ | គណនេយ្យករ | សិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយ ធ្វើសកម្មភាពផ្សព្វផ្សាយ និងរៃអង្គាសថវិកា |
| ៤ | ជំនួយការគណនេយ្យករ | ធ្វើការបូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល និងចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយ |
| ៥ | រដ្ឋបាល | ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬភាគីពាក់ព័ន្ធដើម្បីស្នើសុំកិច្ចសហការរៀបចំលើកិច្ចការរដ្ឋបាល ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជន |
| ៦ | ជំនួយការរដ្ឋបាល | ជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាន និងការរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ(សម្ភារៈ ការតុបតែង ទីតាំង ឯកសារ វត្ថុអនុស្សាវរីយ៍ រង្វាន់ផ្សេងៗ) |
| ៧ | អ្នកសម្របសម្រួល | ដឹកនាំក្រុមការងារទៅកាន់ទីតាំងកម្មវិធី និងសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយ |
| ៨ | ជំនួយការអ្នកសម្របសម្រួល | រៀបចំពិធីបិទកម្មវិធី ថតរូប និងថតវីដេអូជាកម្រងអនុស្សាវរីយ៍ និងកិច្ចការសម្របសម្រួលផ្សេងៗ |

### ខ. អង្គការលេខ




## ២.២. ការប្រើប្រាស់ផែនការពេលវេលា

ពេលវេលាដែលប្រើប្រាស់នៅក្នុងគម្រោងនេះ ត្រូវបានរៀបរាប់តាមរយៈតារាងផែនការនៃពេលវេលាខាងក្រោម៖

| ល.រ | ផែនការសកម្មភាព | ចំនួនថ្ងៃ | ខែ ឧសភា | | | | ខែ មិថុនា | | | | ខែ កក្កដា | | | | ខែ សីហា | | | | ខែ កញ្ញា | | | | ខែ តុលា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | |
| | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។ | ១៣៦ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១ | បង្កើតក្រុមការងារ ធ្វើផែនការគម្រោង បែងចែកភារកិច្ច តួនាទីសម្រាប់សមាជិកម្នាក់ៗចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។ | ៣១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ១.២ | ក្រុមការងារសិក្សានិងវាយតម្លៃអំពីតម្រូវការនៃការចំណាយធ្វើសកម្មភាពផ្សព្វផ្សាយនិងវៃអង្គាសថវិកាចាប់ពីសប្តាហ៍ទី១ ដល់សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៦។ | ៣០ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៣ | ទំនាក់ទំនងទៅកាន់ស្ថាប័ន ឬអ្នកពាក់ព័ន្ធដើម្បីស្នើសុំការសហការ និងរៀបចំលើកិច្ចការរដ្ឋបាល ចាប់ពីសប្តាហ៍ទី១ ខែកក្កដា ដល់សប្តាហ៍ទី២ ខែសីហា ឆ្នាំ២០២៦។ | ៤៥ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៤ | ការជូនដំណឹងដល់ប្រជាជនក្នុងមូលដ្ឋាន និង ការរៀបចំនានាសម្រាប់ថ្ងៃចុះផ្សព្វផ្សាយ (សម្ភារ : ការតុបតែង ទីតាំង ឯកសារវត្ថុអនុស្សាវរីរង្វាន់ផ្សេងៗ) ចាប់ពីសប្តាហ៍ទី៣ ខែសីហា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។ | ៣០ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ២ | ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។ | ១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ | ការដឹកនាំក្រុមការងារទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅដោយមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមុនម៉ោង៧ព្រឹក រួចសមាជិកម្នាក់ៗចាប់ផ្តើមអនុវត្តភារកិច្ចទៅតាមតួនាទីរបស់ខ្លួនក្នុងសប្តាហ៍ ទី៣ ខែកញ្ញា ឆ្នាំ២០២៦។ | ១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ២.២ | ការសម្របសម្រួលដល់បងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាននិង ភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងការផ្សព្វផ្សាយដែលបានចំនួនចន្លោះពី៥០ ទៅ៦០នាក់ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។ | ១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ២.៣ | ការផ្សព្វផ្សាយបញ្ហាអូទីស្សឹមជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋាននៅមណ្ឌលសុខភាពក្រុងតាខ្មៅចំនួនមួយថ្ងៃ ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។ | ១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ២.៤ | រៀបចំពិធីបិទកម្មវិធី និងថតរូបជាអនុស្សាវរីយ៍ក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦។ | ១ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ៣ | ត្រួតពិនិត្យ ការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារៈជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់ សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។ | ២៣ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១ | ក្រុមការងារធ្វើការបូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល ចងក្រងជារូបភាពនិងវីដេអូសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។ | ៧ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.២ | រៀបចំរបាយការណ៍ស្តីពីសកម្មភាពផ្សព្វផ្សាយក្នុងសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។ | ៧ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.៣ | ពិនិត្យ និងកែសម្រួលរបាយការណ៍ឲ្យមានភាពត្រឹមត្រូវ និងស្របតាមគោលបំណងនៅក្នុងសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។ | ៧ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.៤ | ប្រគល់របាយការណ៍ជូនស្ថាប័នពាក់ព័ន្ធ និងផ្សព្វផ្សាយលទ្ធផលទៅកាន់សាធារណជននៅត្រឹមសប្តាហទី៣ ខែតុលា ឆ្នាំ២០២៦។ | ២ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | |

## ២.៣. ការប្រើប្រាស់ធនធានគម្រោង

កញ្ចប់ថវិកាដែលជាការចូលរួមចំណែកពីអង្គការ ADD Cambodia ដៃគូសហការនិងសប្បុរសជនទាំងអស់ត្រូវបានយកមកប្រើប្រាស់លើការចំណាយខាងក្រោម៖

| ល.រ | មុខចំណាយ | បរិមាណ | ឯកតា | តម្លៃឯកតា (៛) | តម្លៃសរុប (៛) |
|---|---|---|---|---|---|
| I | ចំណាយទូទៅ | | | | |
| 1 | សន្លឹកផ្សព្វផ្សាយចែកជូនប្រជាពលរដ្ឋ | 200 | សន្លឹក | 500 | 100.000 |
| 2 | សៀវភៅព័ត៌មានអំពីអូទីស្សឹម | 100 | ក្បាល | 600 | 60.000 |
| 3 | បដាធំសម្រាប់ប្រកចូលកម្មវិធី | 1 | ផ្ទាំង | 60.000 | 60.000 |
| 4 | សៀវភៅចុះឈ្មោះអ្នកចូលរួម | 2 | ក្បាល | 8.000 | 16.000 |
| 5 | ការជួលសម្ភារៈផ្សព្វផ្សាយ(តុ កៅអី Projector,Tripod ,Speaker/Mic ) | 1 | ថ្ងៃ | 300.000 | 300.000 |
| 6 | បែបបទវាយតម្លៃ/ស្ទង់មតិ | 140 | សន្លឹក | 500 | 70.000 |
| 7 | ស្លាកសញ្ញា ឬសម្ភារផ្សព្វផ្សាយមានរូបភាព | 2 | ឈុត | 40.000 | 80.000 |
| 8 | ស្ទីគ័រចែកជូនកុមារ | 20 | បន្ទះ | 3.000 | 60.000 |
| 9 | ទឹកសុទ្ធ(៥០០ ម.ល) | 10 | កេស | 30.000 | 300.000 |
| 10 | កន្ត្រកផ្លែឈើ | 3 | កន្ត្រក | 80.000 | 240.000 |
| 11 | បាច់ផ្កា | 3 | បាច់ | 40.000 | 120.000 |
| 12 | អាហារសម្រន់សម្រាប់ក្រុមការងារ | 20 | កញ្ចប់ | 6.000 | 120.000 |
| 13 | ផ្សេងៗ | | | | 100.000 |
| | | | | តម្លៃសរុប(I) | 1.626.000 |
| II | សម្ភារៈឧបត្ថម្ភដល់មណ្ឌលសុខភាព | | | | |
| 1 | ម៉ាស់ | 15 | ប្រអប់ | 5.000 | 75.000 |
| 2 | ស្រោមដៃ | 10 | ប្រអប់ | 20.000 | 200.000 |
| 3 | ក្រដាសជូតមាត់ | 5 | យួរ | 10.000 | 50.000 |
| 4 | អាល់កុល | 10 | លីត្រ | 5.000 | 50.000 |
| 5 | ធុងសំរាម | 3 | ធុង | 5.000 | 15.000 |
| | | | | តម្លៃសរុប(II) | 390.000 |
| | | | | សរុបថវិកាចំណាយរួម( I + II ) | 2.016.000 |

## ២.៤. ការកំណត់ប្រភពថវិកា

ចំពោះថវិកាដែលទទួលបានទាំងអស់ត្រូវបានចាត់ចែងលើការប្រើប្រាស់ទៅតាមគោលដៅនីមួយៗ ដូចខាងក្រោម៖

- **គោលដៅទី១** : បង្កើតក្រុមការងារ សិក្សានិងរៀបចំផែនការ និងត្រៀមការងារផ្សេងៗមុនថ្ងៃផ្សព្វផ្សាយចាប់ពីសប្តាហ៍ទី១ ខែឧសភា ដល់ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦ទទួលបានប្រភពថវិកាពី៖
  - ដៃគូសហការ ( BABY OUTLET )
- **គោលដៅទី២** : ដឹកនាំក្រុមការងារចុះធ្វើការផ្សព្វផ្សាយក្នុងសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៦ទទួលបានប្រភពថវិកាពី៖
  - អង្គការ ADD Cambodia ( Action on Disability and development Cambodia )
- **និងគោលដៅទី៣** : ត្រួតពិនិត្យ ការចំណាយនិងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធនិងសាធារជនបានជ្រាបចាប់ពីសប្តាហ៍ទី៤ ខែកញ្ញា ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។
  - មូលនិធិអែអង្គាសពីសប្បុរសជន។

## ២.៥. ការតាមដាន ការត្រួតពិនិត្យ និងការតាមដានបន្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគម្រោង ដើម្បីធានាឱ្យបានថា គម្រោងនឹងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

### ក. ការតាមដាន

ប្រធានគម្រោងចាំបាច់ត្រូវប្រើការតាមដានគ្រប់សកម្មភាពនៃដំណើរការចាប់ផ្តើមអនុវត្តគម្រោង តាំងពីការជ្រើសរើសក្រុមការងារ វាគ្មិន អ្នកជំនាញដើម្បីសិក្សាទៅលើប្រធានបទ រៀបចំឯកសារបណ្តុះបណ្តាលនិងសិក្សាទីតាំងផ្សព្វផ្សាយ តម្លៃ ចំនួនឧបករណ៍-សម្ភារៈ។ លើសពីនេះប្រធានគម្រោងត្រូវធ្វើការពិនិត្យទៅលើហានិភ័យដែលនឹងអាចកើតមានឡើងក្នុងការអនុវត្តគម្រោង ហើយមានករណីចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពយ៉ាងតិចរៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីធានាបានថាក្រុមការងារទាំងអស់បានអនុវត្តទៅតាមសកម្មភាពដែលបានដាក់ចេញប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

### ខ. ការត្រួតពិនិត្យ

ការត្រួតពិនិត្យគម្រោងនឹងត្រូវអនុវត្តជា ៤ ដំណាក់កាល ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាព។ ជាដំបូង ការវាយតម្លៃមុនចាប់ផ្តើម (Pre-Evaluation )ផ្តោតលើការប្រជុំកំណត់លក្ខខណ្ឌការងារ និងបំពេញចំណុចខ្វះខាត។ បន្ទាប់មក ការវាយតម្លៃពេលអនុវត្ត ( On-going Evaluation )ត្រូវបានធ្វើឡើងដើម្បីតាមដាន និងកែសម្រួលបញ្ហាចំពោះមុខជាប្រចាំ។ នៅពេលបញ្ចប់សកម្មភាពការវាយតម្លៃ( ( End Evaluation )

នឹងត្រូវធ្វើឡើងដើម្បីផ្ទៀងផ្ទាត់លទ្ធផលធៀបនឹងគោលបំណង និងការរំពឹងទុករបស់គម្រោង។ ជាចុងក្រោយ ការវាយតម្លៃក្រោយបញ្ចប់(Post-Evaluation )ជាការពិនិត្យលើផលប៉ះពាល់ជារួម និងនិរន្តរភាពនៃសមិទ្ធផល ដែលសម្រេចបាន។ យន្តការនេះជួយឱ្យប្រធានគម្រោង និងក្រុមការងារអាចគ្រប់គ្រងហានិភ័យ និងសម្រេចបាននូវគោលដៅប្រកបដោយគណនេយ្យភាពខ្ពស់។

១. Pre-Evaluation : វាយតម្លៃមុនពេលចាប់ផ្តើមគម្រោង (កំណត់លក្ខខណ្ឌការងារ និងបំពេញចំណុចខ្វះខាត)។

២. On-going Evaluation : វាយតម្លៃពេលអនុវត្តគម្រោង (តាមដាន និងកែសម្រួលបញ្ហា)។

៣. End Evaluation : វាយតម្លៃបន្ទាប់ពីសកម្មភាពចម្បងៗនៃគម្រោងត្រូវបានអនុវត្តរួចរាល់។

៤. Post-Evaluation : វាយតម្លៃលទ្ធផលក្រោយបញ្ចប់គម្រោងផ្ទៀងផ្ទាត់ដោយ Impact Indicator។

### គ. ការតាមដានបន្ត

ក្រោយបញ្ចប់កម្មវិធីផ្សព្វផ្សាយរយៈពេល ៤សប្តាហ៍ ក្រុមការងារនឹងចុះអនុវត្តការតាមដានភ្លាមៗ តាមរយៈការដាក់ចេញនូវកម្រងសំណួរស្ទាបស្ទង់មតិ (Survey/Post-test) ទៅកាន់អ្នកចូលរួមទាំងអស់។ ការធ្វើបែបនេះ គឺដើម្បីវាយតម្លៃពីកម្រិតនៃការយល់ដឹងដែលទទួលបានពីកម្មវិធី និងការផ្លាស់ប្តូរឥរិយាបថចំពោះបញ្ហាអូទីស៊ីឹម។ ទិន្នន័យដែលប្រមូលបាននឹងត្រូវចងក្រងជារបាយការណ៍វឌ្ឍនភាព និងសមិទ្ធផល ដើម្បីបង្ហាញពីតម្លាភាព និងប្រសិទ្ធភាពនៃគម្រោងជូនដល់ម្ចាស់ឧបត្ថម្ភ សប្បុរសជន និងសាធារណជនឱ្យបានជ្រាបជាព័ត៌មាន។

## ២.៦. ការបញ្ចប់គម្រោង

ក្រោយបញ្ចប់ការអនុវត្តគម្រោង ប្រធានគម្រោងនឹងរៀបចំរបាយការណ៍បូកសរុបលទ្ធផល ដោយភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុរួមមានវិក្កយបត្រចំណាយ ព្រមទាំងកម្រងរូបភាព និងវីដេអូសកម្មភាព ដើម្បីដាក់ជូនភាគីពាក់ព័ន្ធរួមមាន អ្នកឧបត្ថម្ភគម្រោង សប្បុរសជន និងសាធារណជន ដើម្បីជ្រាបជាព័ត៌មាន និងបង្ហាញពីតម្លាភាពនៃគម្រោង។

### ក. ប្រភេទនៃការបញ្ចប់គម្រោង

ដោយមានការជួយជ្រោមជ្រែងពីអ្នកពាក់ព័ន្ធមានអាជ្ញាធរមូលដ្ឋាន ប្រធានមណ្ឌលសុខភាពម្ចាស់ឧបត្ថម្ភគម្រោងពិសេសការចូលរួមពីប្រជាជនមូលដ្ឋានបានធ្វើឱ្យគម្រោងបញ្ចប់ដោយដំណើរអស់ទៅដោយហេតុថាផែនការបានបំពេញចប់សព្វគ្រប់ស្របទៅតាមពេលវេលាដូចដែលបានគ្រោងទុក។

### ខ. ដំណើរការបញ្ចប់គម្រោង

រាល់សម្ភារៈនិងបរិក្ខារដែលនៅសល់ក្រោយពេញបញ្ចប់គម្រោង នឹងត្រូវផ្ទេរជាកម្មសិទ្ធិជូនមណ្ឌលសុខភាពក្រុងតាខ្មៅក្នុងខេត្តកណ្តាលចាត់ចែងបន្ត។

### គ. ការផ្ទេរគម្រោង

ក្រោយបញ្ចប់ការផ្សព្វផ្សាយ គម្រោងនឹងផ្ទេរបច្ចេកទេសទៅកាន់មណ្ឌលសុខភាពក្រុងតាខ្មៅ តាមរយៈការបណ្តុះបណ្តាលបុគ្គលិកឱ្យមានជំនាញម្ចាស់ការ និងការប្រគល់សៀវភៅណែនាំ ដើម្បីធានាឱ្យការអនុវត្តបន្តមានស្តង់ដារ។ ជាមួយគ្នានេះ គម្រោងនឹងជួយបញ្ចូលការងារនេះទៅក្នុងផែនការប្រចាំឆ្នាំរបស់មណ្ឌលសុខភាព ដើម្បីធានានិរន្តភាព និងប្រសិទ្ធភាពសេវាជូនប្រជាពលរដ្ឋ។

## ២.៧. ការវិភាគ SWOT

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - ក្រុមការងារសាមគ្គីគ្នាបានល្អ<br>- ការចូលរួមពីសិក្ខាកាមយ៉ាងសកម្ម<br>- ការចែករំលែកបទពិសោធន៍ផ្ទាល់ពីអាណាព្យាបាលដែលមានបុត្រាបុត្រីមានបញ្ហា Autism | - ថវិកាមានកម្រិត<br>- ទីតាំងរៀបចំផ្សព្វផ្សាយមានទំហំតូច<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត |
| **ឱកាស** | **ការគំរាមកំហែង** |
| - មានការគាំទ្រពីក្រសួងសុខាភិបាល<br>- មានការគាំទ្រពីក្រសួងអប់រំ<br>- មានការគាំទ្រពីអ្នកពាក់ព័ន្ធ | - អាកាសធាតុប្រែប្រួល<br>- ប្រជាពលរដ្ឋមិនចាប់អារម្មណ៍ |

# សេចក្តីសន្និដ្ឋាន

ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន យើងសង្កេតឃើញថាសាធារណជនភាគច្រើនមិនទាន់ទទួលបានព័ត៌មានទូលំទូលាយទៅលើការយល់ដឹងអំពីបញ្ហាអូទីស្សឹម (Autism) នៅឡើយ ដោយពិនិត្យឃើញបែបនេះទើបក្រុមរបស់យើងខ្ញុំបានរៀបចំឱ្យគម្រោងចុះផ្សព្វផ្សាយ ដើម្បីជាការចែករំលែកនូវចំណេះដឹង បទពិសោធន៍របស់មាតាបិតា និងអាណាព្យាបាលកុមារដែលមានអូទីស្សឹមផ្ទាល់ ជូនដល់សាធារណៈជន។ គម្រោង«ការផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាអូទីស្សឹមនៅមណ្ឌលសុខភាពក្រុងតាខ្មៅក្នុងខេត្តកណ្តាល» មានរយៈពេល២៣សប្តាហ៍ដោយគិតចាប់ពីសប្តាហ៍ទី១នៃខែឧសភា រហូតដល់សប្តាហ៍ទី៣នៃខែតុលា។ តាមរយៈសកម្មភាពផ្សព្វផ្សាយនេះដែរ ជាការរួមចំណែកមួយទៅនឹងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការខិតខំប្រឹងប្រែងបញ្ជ្រាបការយល់ដឹង ការគោរពសិទ្ធ បញ្ឈប់ការរើសអើង និងរៀបចំមជ្ឈដ្ឋានដ៏សមស្របមួយសម្រាប់កុមារដែលមានអូទីស្សឹម ដូចកាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ កន្លងទៅ កម្ពុជាបានប្រារព្ធទិវាជនមានពិការភាពអូទីស្សឹម(Autism) និងដោនស៊ីនដ្រូម (Down Syndrome) លើកទី១២ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានការចូលរួមយ៉ាងច្រើនពីមាតា បិតា អាណាព្យាបាលកុមារអូទីស្សឹម និងភាគីពាក់ព័ន្ធនានាផងដែរ។

ក្រុមការងារយើងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា យុទ្ធនាការផ្សព្វផ្សាយនាពេលនេះ នឹងក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញឱ្យមានគម្រោងថ្មីៗបន្ថែមទៀត ដើម្បីរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពសង្គមកម្ពុជាឱ្យកាន់តែរីកចម្រើន និងប្រសើរឡើងជាលំដាប់។